ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៨ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតអនុគណៈកម្មាធិការបច្ចេកទេសចម្រុះ នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសម្រេចលេខ ១៤៨សសរ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការបច្ចេកទេសចម្រុះទទួលបន្ទុកការកំណត់ព្រំដែន និងការអភិវឌ្ឍរួមគ្នា លើធនធានប្រេងកាត នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ
- បានឃើញតម្រូវការចាំបាច់ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

## សម្រេច

**ប្រការ ១:** បង្កើតអនុគណៈកម្មាធិការបច្ចេកទេសចម្រុះ នៅក្នុងតំបន់ទាមទារ ដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ ដែលមានសមាសភាពដូចតទៅ÷

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | ហួ ទិចិត្រ | រដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | ប្រធាន |
| ២- | ឯកឧត្តម | ឡុង វិសាលោ | រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការ | អនុប្រធាន |

www.pheakdeylaw.com

| | | | | |
|---|---|---|---|---|
| ៣- | ឯកឧត្តម | នាង ផាត | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | អនុប្រធាន |
| ៤- | ឯកឧត្តម | តឹករ៉េត សំរេច | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥- | ឯកឧត្តម | ស៊ុខ ខាវ៉ាន់ | រដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៦- | ឯកឧត្តម/លោកជំទាវ ឯកអគ្គរាជទូត ប្រចាំព្រះរាជាណាចក្រថៃ | | | សមាជិក |
| ៧- | ឯកឧត្តម | ឡាំ ជា | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៨- | ឯកឧត្តម | អ៊ិត សុត្ថា | ទីប្រឹក្សាអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន និង ជាអនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដីនគរូប នីយកម្ម និងសំណង់ | សមាជិក |
| ៩- | ឯកឧត្តម | ភៅ ឆារ៉ូ | អនុរដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១០- | ឯកឧត្តម | ឃុន បូររិទ្ធ | អគ្គលេខាធិការរង គណៈកម្មាធិការជាតិសន្តិសុខ លម្ហសមុទ្រ | សមាជិក |
| ១១- | ឯកឧត្តម | ស៊ា ម៉ៅ | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ១២- | ឯកឧត្តម | ជៀប សួរ | អគ្គនាយក នៃអគ្គនាយកដ្ឋានប្រេងកាត ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៣- | ឯកឧត្តម | គង់ ច័ន្ទទាសនា | ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងជា ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក និងជាលេខាធិការ |
| ១៤- | ឯកឧត្តម | ហាក់ សុខហេង | អគ្គលេខាធិការរង ក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក និងជាលេខាធិការ |
| ១៥- | លោក | ជា សុជាតិ | ប្រធាននាយកដ្ឋានកិច្ចការប្រេងកាត អន្តរជាតិ ក្រសួងរ៉ែ និងថាមពល | សហជិក |
| ១៦- | លោក | កែវ ទិសិដ្ឋ | ប្រធាននាយកដ្ឋានច្បាប់-កុងស៊ុល នៃក្រសួង ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៧- | លោក | ហួយ ទុត្ថា | ប្រធាននាយកដ្ឋានសិក្សាស្រាវជ្រាវប្រេងកាត ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៨- | លោកស្រី | យ៉ែម កាន់នីកា | ប្រធាននាយកដ្ឋាននីតិកម្ម ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៩- | លោក | ឈឹម ទត្ថា | អនុប្រធាននាយកដ្ឋានកិច្ចការប្រេងកាតអន្តរជាតិ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ២០- | លោក | កែវ ទិសិដ្ឋ | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងព័ត៌មានវិទ្យា ក្រសួងរ៉ែ និងថាមពល | សមាជិក និងជាលេខាធិការ |

**ប្រការ ២:** អនុគណៈកម្មាធិការបច្ចេកទេសបម្រុះ នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ មាន ភារកិច្ចដូចតទៅ÷

(ក)- ជាយន្តការឆ្លើយតប ក្នុងកិច្ចសហប្រតិបត្តិការ ជាមួយព្រះរាជាណាចក្រថៃ ក្នុងដំណើរការចរចា ដោះស្រាយតំបន់ដែនសមុទ្រទាមទារត្រួតគ្នា។/៤

(ខ)- ជាយន្តការសមភាគីជាមួយអនុគណៈកម្មាធិការបច្ចេកទេសចម្រុះថ្មី ដែលព្រះរាជាណាចក្រថៃ ទើបនឹងបង្កើតឡើង។

**ប្រការ ៣:** គ្រប់សមាជិកនៃអនុគណៈកម្មាធិការបច្ចេកទេសចម្រុះ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញ របស់ប្រធាន ឬ អនុប្រធាន។

**ប្រការ ៤:** អនុគណៈកម្មាធិការបច្ចេកទេសចម្រុះ មានទីស្នាក់ការរបស់ខ្លួន នៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រា របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ ៥:** អនុគណៈកម្មាធិការបច្ចេកទេសចម្រុះ មានសិទ្ធិប្រើប្រាស់មូលនិធិរបស់គណៈកម្មាធិការបច្ចេកទេសចម្រុះ ទទួលបន្ទុកការកំណត់ព្រំដែន និងការអភិវឌ្ឍរួមគ្នា លើធនធានប្រេងកាត នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ សម្រាប់បំពេញការងាររបស់ខ្លួន។

**ប្រការ ៦:** សេចក្តីសម្រេចលេខ ០៧ សសរ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០២ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ[illegible] ឆ្នាំ ២០១៥

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com